**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈរដ្ឋមន្ត្រី**

**ក្រសួងបរិស្ថាន**

លេខ: ០៦០ ប្រ.ក ........ប.ស្ត

រាជធានីភ្នំពេញ ថ្ងៃទី ២១.... ខែ មិថុនា........ឆ្នាំ២០០៦

# ប្រកាស

## ស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "អូរចាយ"

## ឃុំថ្មកែវ និងឃុំសន្តិភាព ស្រុកសៀមប៉ាង នៃតំបន់ឧទ្យានជាតិវីរៈជ័យ ស្ថិតក្នុងភូមិសាស្ត្រខេត្តស្ទឹងត្រែង

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦-៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន
- បានឃើញសេចក្តីជូនដំណឹងលេខ ២៩៥ សជណ.កស ចុះថ្ងៃទី ១៦ ខែ មិនា ឆ្នាំ២០០១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ផ្អែកតាមតម្រូវការចាំបាច់របស់សហគមន៍មូលដ្ឋានដែលស្ថិតនៅក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ ខេត្តរតនៈគិរី ។

## សំរេច

ប្រការ១:- រៀបចំសហគមន៍តំបន់ការពារធម្មជាតិដែលស្ថិតនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃឧទ្យានជាតិវីរៈជ័យ ឃុំសន្តិភាព និង ឃុំថ្មកែវ នៃស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង មានឈ្មោះថា "**សហគមន៍តំបន់ការពារធម្មជាតិអូរចាយ** " ។

ប្រការ២:- សហគមន៍តំបន់ការពារធម្មជាតិ**អូរចាយ** នៃឧទ្យានជាតិវីរៈជ័យ ស្ថិតក្នុងភូមិសាស្ត្រ ឃុំសន្តិភាព និងឃុំថ្មកែវ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង មានផ្ទៃដី ពីរពាន់ប្រាំបីរយមួយ **(២៨០១) ហិកតា** ដូចបានកំណត់ក្នុងផែនទី ដែលមានអាប់ស៊ីស និងកូអ័រដោនេ ព្រំប្រទល់ ខាងក្រោម :

| ចំណុច | ឈ្មោះទីតាំង | អាប់ស៊ីស X | អូរដោនេ Y |
|---|---|---|---|
| A | មាត់អូរចិនតង់ជាប់ទន្លេសេកុង | ៦៩២៤៩៧ | ១៩៧០២៥៨ |
| B | ក្បាលចំការតាអូនអូរចិនតង់ | ៦៩៥៤៩៤ | ១៩៧៤៨៨៦ |
| C | អូរហុង | ៦៩៥៥១៩ | ១៩៧៤៣៩៤ |
| D | ចំការតាក្តាំងឆ្នាំ២០០២ | ៦៩៥៦៨១ | ១៩៧៤៤០៩ |
| E | ផ្លូវយ៉ាកខ្សែវ | ៦៩៥៧៧៥ | ១៩៧៤៩៧៤ |
| F | ថ្មដាអូរហាតអាត | ០៦៩៧៨៦៩ | ១៩៧១៩៦៨ |
| G | មាត់អូរតេលជាប់អូរចាយ | ០៦៩៩៩៧៣ | ១៩៧៤១៧១ |

<u>ប្រការ៣:</u>- ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ**អូរចាយ** នៃឧទ្យានជាតិវីរៈជ័យ និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះ ត្រូវចុះកិច្ចព្រមព្រៀងជាមួយក្រសួងបរិស្ថាន ហើយសហគមន៍នេះត្រូវមានលក្ខន្តិកៈដោយឡែក ។

<u>ប្រការ៤:</u>- អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានការពារនិងអភិរក្សធម្មជាតិ ប្រធានមន្ទីរបរិស្ថានខេត្តស្ទឹងត្រែង នាយកឧទ្យានជាតិវីរៈជ័យ អង្គភាពពាក់ព័ន្ធ និងសហគមន៍តំបន់ការពារធម្មជាតិ**អូរចាយ** នៃឧទ្យានជាតិវីរៈជ័យ ស្ថិតក្នុងឃុំសន្តិភាព និងឃុំថ្មកែវ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ត្រូវសហការអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*<u>ចំលងជូន:</u>*

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- សាលាខេត្តរតនៈគីរី-ស្ទឹងត្រែង
- គំរោងគ្រប់គ្រងជីវៈចម្រុះ និងឧទ្យានជាតិវីរៈជ័យ
- ដូចប្រការ ៤ " ដើម្បីអនុវត្ត"
- ឯកសារ, កាលប្បវត្តិ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ុក_ម៉ារ៉េត

បណ្ឌិត.ជីវវិទ្យា